00897685

E276/1

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 04 / 2013
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង

---

**អ្នកដាក់ឯកសារ:**
**ការិ.សហព្រះរាជអាជ្ញា:**
លោក Andrew CAYLEY
លោកស្រី ជា លាង

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**ចម្លងជូន:**
**ជនជាប់ចោទ**
ខៀវ សំផន
នួន ជា

**សហមេធាវីជនជាប់ចោទ**
លោក គង់ សំអុន
លោក Arthur VERCKEN
លោក Jacques VERGES
លោក សុន អរុណ
លោក Victor KOPPE

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង*

**ចម្លើយតប**

១. កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ សហមេធាវីការពារជនជាប់ចោទ ខៀវ សំផន("មេធាវីការពារក្តី") បានដាក់ជូននូវសំណើមួយតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ("សំណើ")[1] ដែលស្វែងរកសុំឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង("អង្គជំនុំជម្រះ") នូវសេចក្តីដកស្រង់ចេញពីការធ្វើសម្ភាសន៍របស់សារព័ត៌មានដោយថតជាខ្សែវីដេអូ ("ការធ្វើសម្ភាសន៍")[2]ជាមួយនឹងព្រះបរមរតនកោដ្ឋសម្តេចព្រះរាជបីតា នរោត្តម សីហនុ។ មេធាវីការពារក្តីបានចោទប្រកាន់ថា ព្រះរាជបន្ទូលរបស់ព្រះបរមរតនកោដ្ឋព្រះរាជបីតា កាលពីក្នុងអម្លុងពេលនៃការធ្វើបទសម្ភាសន៍ខាងលើនេះ គឺផ្ទុយគ្នានឹងព្រះរាជបន្ទូលរបស់ព្រះអង្គនៅក្នុងខ្សែវីដេអូមួយផ្សេងទៀត (ឯកសារលេខ D299.1.42R) ដែលសហព្រះរាជអាជ្ញា[3]បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលធ្វើឱ្យមានភាពអវិជ្ជមានដល់តម្លៃភរនីយភាពនៃខ្សែវីដេអូនេះ (ឯកសារលេខ D299.1.42R)[4]។ ជាជម្រើសម្យ៉ាងទៀត មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះចេញដីកាសំរេចឱ្យដកខ្សែវីដេអូ ឯកសារលេខ D299.1.42R នេះ ចេញពីក្នុងសំណុំរឿង។

២. ជាគោលការណ៍ សហព្រះរាជអាជ្ញាមិនមានការជំទាស់អ្វីទៅនឹងការទទួលយកនូវបទសម្ភាសន៍ធ្វើជាភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ នោះឡើយ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា ត្រូវតែធ្វើការកត់សម្គាល់ថាសំណើ នោះ មានលក្ខណៈមិនត្រឹមត្រូវ និងមិនមានសំអាងគ្រប់គ្រាន់។

៣. សំណើនេះ ទំនងជាបានលើកឡើងថា មេធាវីការពារក្តី ដំបូងបានទទួលការជូនដំណឹងស្តីពីវីឌីអូ **D299.1.42R** នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ ដោយមិនមានធ្វើការយោងទៅប្រវត្តិនីតិវិធីពីមុន

---

[1] ឯកសារលេខ **E276** សំណើសុំដាក់ឱ្យពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ នូវបទសម្ភាសន៍ជាមួយ ព្រះបរមរតនកោដ្ឋ ព្រះបីតា នរោត្តម សីហនុ អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង, ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ ។

[2] " ព្រះ នរោត្តម សីហនុ មានព្រះរាជបន្ទូលអំពីជីវិតរស់នៅរបស់ព្រះអង្គ នៅក្រោមរបបខ្មែរក្រហម", ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៩, អង់តែនទី២ Antenne 2 (ដែលអាចរកបាននៅក្នុងគេហទំព័រដែលមានអាសយដ្ឋាន: http://www.ina.fr/video/I06065624)។

[3] ឯកសារលេខ D299.1.42R សង្គ្រាមទ័ពព្រៃ Jungle War [មិនដឹងកាលបរិច្ឆេទ], ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៣ ។ សូមអាន ឯកសារលេខ **E1/168.1** ប្រតិចារិក (ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៣),ទំព័រ២៥, ជួរបន្ទាត់ទី ១៩ ដល់ទំព័រ ២៦, ជួរបន្ទាត់ទី៩។

[4] ឯកសារលេខ **E276** សំណើ កំណត់សំគាល់លេខ១ *ខាងដើម* ត្រង់ទំព័រ៥ ("...គ្មានតម្លៃភរនីភាពដែលអាចផ្តល់ជូនទៅឱ្យសេចក្តីថ្លែង ...ដែលមាននៅក្នុងខ្សែវីដេអូ ឯកសារលេខ D299.1.42R នេះឡើយ...").

នោះទេ[5]។ តាមអង្គហេតុពិត វីឌីអូនេះត្រូវបានដាក់ជូនទៅសហព្រះរាជអាជ្ញា នៅក្នុងបញ្ជីឯកសារដំបូងរបស់ខ្លួន អនុលោមតាមវិធាន ៨០ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[6]។ មេធាវីការពារក្ដីធ្លាប់បានទទួលដំណឹងអំពីខ្លឹមសាររបស់វា និងអំពីចេតនារបស់សហព្រះរាជអាជ្ញាក្នុងការដាក់វីឌីអូនេះនៅចំពោះមុខអង្គជំនុំជម្រះ សម្រាប់រយៈពេល ២៤ខែ។ នៅក្នុងកាលៈទេសៈទាំងនេះ វាមិនទំនងបំផុត ដែលថាមេធាវីការពារក្ដី ក្នុងឋានៈជាភាគីដាក់សំណើ នឹងមានលទ្ធភាព "ពេញចិត្តនឹងអង្គជំនុំជម្រះដែលថា...ដែលបានស្នើសុំភ័ស្តុតាងនោះ គឺមិនអាចមាននៅមុនពេលបើកសវនាការ" តាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្ដីមិនបានផ្ដល់មូលហេតុនាមួយឡើយ ថាតើហេតុអ្វីបានជាបទសម្ភាសន៍នោះ ត្រូវបានរកឃើញនាដំណាក់កាលខាងក្រោយ នៃកិច្ចដំណើរការនីតិវិធី។ តាមពិត សំណើនេះមិនបានលើកឡើងពីលក្ខខណ្ឌតម្រូវ នៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងនេះទាល់តែសោះ។

៤. សហព្រះរាជអាជ្ញា ត្រូវតែសង្កេតផងដែរថា មេធាវីការពារក្ដីតែងតែធ្វើដដែលៗតាមទម្លាប់ក្នុងការជំទាស់ទៅនឹងសំណើតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ជាក់ស្ដែងដោយផ្អែកលើមូលដ្ឋានថាវិធាននេះតម្រូវឲ្យភាគីនានា "ត្រូវតែបង្ហាញឲ្យឃើញថា តើធ្វើដូចម្ដេចទៅ ទោះបីជាមានការអនុវត្តដោយមានការយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ក៏ដោយក៏ ពួកគេមិនអាចមានលទ្ធភាពក្នុងការបញ្ជូនឯកសារទាំងនោះ មុនពេលចាប់ផ្ដើមការជំនុំជម្រះក្ដីបានដែរ"[7]។

[5] **E276** *ដដែលដូចមុខ* ត្រង់កថាខណ្ឌ១។

[6] **E9/31** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់សវនាការ ស្របតាមវិធាន ៨០(៣), ១៩ មេសា ២០១១។

[7] ឯកសារលេខ **E276** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១។

៥. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះមេត្តា៖

ក. **បដិសេធ**នូវសំណើនេះ។ និង

ខ. **ទទួលយក**នូវការធ្វើសម្អាសន៍នេះដោយផ្អែកលើការផ្តួចផ្តើមគំនិតរបស់ខ្លួនផ្ទាល់ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |